# ជំនួបទ្វេភាគី រវាង ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ជាមួយ ឯកឧត្តម Datuk Seri Panglima Wilfred Madius Tangau រដ្ឋមន្ត្រីក្រសួងវិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ នៃប្រទេស ម៉ាឡេស៊ី



ក្នុងជំនួបទ្វេភាគី រវាងឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ជាមួយ ឯកឧត្តម Datuk Seri Panglima Wilfred Madius Tangau រដ្ឋមន្ត្រីក្រសួងវិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ នៃប្រទេសម៉ាឡេស៊ី ក្នុងឱកាស ភាគីទាំងពីរអញ្ជើញចូលរួមកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ានស្តីពីបច្ចេកវិទ្យា និងវិទ្យាសាស្ត្រ AMMST លើកទី១៧ នៅប្រទេសភូមា បានផ្តោតការ យកចិត្តទុកដាក់ទៅលើ ការពង្រឹងកិច្ចសហ ប្រតិបត្តិការផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រវាងប្រទេសទាំងពីរឲ្យមានការរីក ចម្រើន ក្នុងផលប្រយោជន៍ទៅវិញទៅមក។



គួរបញ្ជាក់ថា៖ដើម្បីឲ្យកម្ពុជា មានការវិវឌ្ឍផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដើរបាន លឿនដូច ប្រទេសក្នុងតំបន់ និងពិភពលោក កម្ពុជាត្រូវការកសាងសត្ថភាពធនធានមនុស្សផ្នែកសិក្សាស្រាវជ្រាវ នវានុវត្តន៍ ហេដ្ឋារចនាសម្ព័ន្ធវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាទាំងទុន និង រឹង ។ ក្នុងនោះ ការផ្ទេរបច្ចេកវិទ្យា-ការវិនិយោគបច្ចេកវិទ្យា-យន្តការគាំទ្រ -ការលើកទឹកចិត្តដល់ការស្រាវជ្រាវ-ការចែករំ លែកបទពិសោធន៍ -ចំណេះដឹង -ការផ្ទេរបច្ចេកវិទ្យា -ពិព័រណ៌ បច្ចេកវិទ្យា-ការភ្ជាប់ទំនាក់ទំនងអ្នកវិទ្យាសាស្ត្រ វ័យក្មេងក្នុងក្របខណ្ឌជាតិ និងអន្តរជាតិ ជាបញ្ហាគន្លឹះមួយដែលត្រូវមានយន្តការគាំទ្រសមស្រប និងសហប្រតិបត្តិការជាមួយប្រទេសជាដៃគូរ ។



ជាមួយគ្នានេះវិស័យសំខាន់ៗពាក់ព័ន្ធ ស្តង់ដារ -វាយតម្លៃទទួលស្គាល់ -ចំណីអាហារ -កម្មសិទ្ធិបញ្ញា -សួនឧស្សាហកម្ម-មន្ទីរពិសោធន៍ -វិទ្យាស្ថានសិក្សាស្រាវជ្រាវ -ផ្ទាលបណ្តុះ បច្ចេកវិទ្យា ធុរកិច្ច និងសហគ្រិនភាព ជាកត្តាសំខាន់ដែលត្រូវ ពង្រឹងពង្រីក និងកសាងសមត្ថភាពបន្ថែម។ ជាចុងក្រោយ ភាគីទាំងពីរបានឯកភាពក្នុងការជំរុញការចុះ អនុស្សារណៈយោគយល់គ្នាឲ្យបានឆាប់នាពេលខាងមុខនេះ ។